ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧៧៨ សហវ.ហក

នាយកដ្ឋាន ខ.ទ.អ
ការិយាល័យរដ្ឋបាល
លិខិតចូល លេខ: ១៩១
ថ្ងៃទី ២៤ ខែ ០២ ១៥ ម៉ោង

មកដល់ក្រសួង អ.យ.ក
ថ្ងៃទី 11 ខែ 02 ឆ្នាំ 2015
ម៉ោង នាទី ចុះលេខ 203

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៥

គោរពជូន

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

**កម្មវត្ថុ ÷** ករណីសំណើសុំគោលការណ៍ដំឡើង២៥% លើប្រាក់អាហារូបករណ៍របស់និស្សិតបរទេស ។

**យោង ÷** -លិខិតលេខ៥៤៥៣អយក.ទវអ ចុះថ្ងៃទី០២-១២-២០១៤ របស់ក្រសួងអប់រំ យុវជន និងកីឡា

-លិខិតលេខ១៤៨៧/១៤ខ.ឧ ចុះថ្ងៃទី០៨-១២-២០១៤ របស់ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានពិនិត្យនិងឯកភាពជាគោលការណ៍ឱ្យក្រសួងអប់រំ យុវជននិងកីឡាដំឡើង ២៥% លើប្រាក់អាហារូបករណ៍របស់និស្សិតបរទេសដែលមកសិក្សាក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពីខែមករា ឆ្នាំ ២០១៥ ឱ្យដល់ចំនួនដូចខាងក្រោម ÷

១ - ថ្នាក់បរិញ្ញាបត្រ ចំនួន ១៥០ ដុល្លារ/ម្នាក់/១ខែ

២ - ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន ១៧៣ ដុល្លារ/ម្នាក់/១ខែ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន ÷
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯ.ឧ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- ឯកសារ-កាលប្បវត្តិ

12/2

24/02/15

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com